Nº 32
31-8-97

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៥ លេខ ៣២ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៩៧

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

LAN

GH-KIMPO

ក

មាតិកា

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៥.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧ /១៦១ តែងតាំង ឯកឧត្តម ស៊ុំ ម៉ានិត ជាអគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន	១៩០២
២៥.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៦២ តែងតាំងនិងតម្លើងឋានៈ ឯកឧត្តមទេព ដារ៉ុង ជាអគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន	១៩០៣
២៥.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៦៣ តែងតាំងនិងតម្លើងឋានៈ ឯកឧត្តមឧត្តមសេនីយត្រី ស្លាដារីម៉ាត់លីរុណា ជាអគ្គលេខាធិការរង អាជ្ញាធរជាតិ ប្រយុទ្ធ ប្រឆាំងគ្រឿងញៀន	១៩០៤
២៧.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៦៦ តម្លើងឋានៈឯកឧត្តមបណ្ឌិត ចែម វិឡា ជាអគ្គលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៩០៥
២៧.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៦៧ តម្លើងឋានៈឯកឧត្តម ជាង អេងងួន ជាអគ្គលេខាធិការរងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	១៩០៦
២៨.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៩៥ តែងតាំងឯកឧត្តម គង់ ឆាន ជាអនុប្រធានទី ១ យុវនីតិសម្បទា	១៩០៧
២៨.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៩៦ តែងតាំងឯកឧត្តម ពៅ សាមី ជាអនុប្រធានទី ២យុវនីតិសម្បទា	១៩០៨
២៨.៨.១៩៩៧	ព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៩៧ តែងតាំងឯកឧត្តម អ៊ឹង ហួត នាយករដ្ឋមន្ត្រីទី១ ឱ្យទទួលភារកិច្ច ជាសហប្រធានគណៈកម្មាធិការជាតិ ក្រុមប្រឹក្សាជាតិ និង គណៈកម្មាធិការនានាទាំងអស់ ជំនួស	

	សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធ	១៩០៩
២៨-៨-១៩៩៧	ព្រះរាជក្រឹត្យ ជស .រកត .០៨៩៧.១៩៨ តែងតាំងឯកឧត្តម ហេង វង្សប៊ុនឆាត ជាឧត្តមទីប្រឹក្សារបស់រាជរដ្ឋាភិបាល	១៩១០
២៨-៨-១៩៩៧	ព្រះរាជក្រឹត្យ ជស .រកត .០៨៩៧ .១៩៩ តែងតាំងឯកឧត្តម សុន គន្ធរ ជាទីប្រឹក្សារបស់រាជរដ្ឋាភិបាល	១៩១១
២៨-៨-១៩៩៧	KRET NS /KRT/ 0897 /60 Nommons Monsieur KYLE GILLESPLE Offier de l'Ordre Royal du SAHAMETREI	១៩១២

II-រាជរដ្ឋាភិបាល

១- អនុក្រឹត្យ

២៧-៨-៩៧	អនុក្រឹត្យលេខ៤៤ អនក្រ បក ស្តីពីការផ្ទេរឥណទាន	១៩១២
២៩-៨-៩៧	អនុក្រឹត្យលេខ៤៥ អនក្រ បក ស្តីពីការរំសាយ និង បង្កើតទីស្នាក់ការត្រួតពិនិត្យ តាមច្រកព្រំដែន និង ផ្លូវគមនាគមន៍នៅ ទូទាំងព្រះរាជាណាចក្រកម្ពុជា	១៩១៤

២-សេចក្តីសំរេច

២៩-៨-១៩៩៧	សេចក្តីសំរេចលេខ ២៩ សសរ ស្តីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈ ជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ក្រុមហ៊ុនវិនិយោគនានា	១៩២៥

៣- សារាចរ

២៧-៨-៩៧	សារាចរលេខ ០៦ សរ ស្តីពីភារកិច្ចធំៗក្នុងការរៀបចំបរិយាកាសនយោបាយ អព្យាក្រឹត្យនិងសន្តិសុខសាធារណៈ	១៩២៧

III- ការងារបណ្ដាក្រសួង

១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

២៥.៨.៩៧	ប្រកាសលេខ ៧៧៨ ជក. ប្រក អនុញ្ញាតឱ្យក្រុមហ៊ុនហ្គោលដ៍តិក (ខេមបូឌា) ហ្គាមីនថ៍មែនញូហ្វាក់ធើរីង អិលធីឌី តំណាងដោយ លោក LEE YUET KAU សញ្ជាតិអង់គ្លេស បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ	១៩៣២

២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្ដីសំរេច

២៩.៨.៩៧	សេចក្ដីសំរេចលេខ ៤៨៦ សសរ.មស.ក្រខ ស្ដីពីការបែងចែកសិស្សនិស្សិតចំនួន ១៤ នាក់ដែលទើបបញ្ចប់ការសិក្សាពីប្រទេសក្រៅ	១៩៣៥

I- ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស.រកត.០៨៩៧.១៦១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់ -

មាត្រា ១.- តែងតាំងឯកឧត្តម **ស៊ី ម៉ារិន** ជាអគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៥ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ នស.រកត.០៨៩៧.១៦២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំង និងតម្លើងឋានៈឯកឧត្តម **នេត ដារ៉ុន** ជាអគ្គលេខាធិការរង អាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះ រាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៥ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស.រកត.០៨៩៧.១៦៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- ត្រូវបានតែងតាំង និងតម្លើងឋានៈឯកឧត្តមឧត្តមសេនីយ៍ត្រី **ស្នងដាវី ម៉ៅត់លីរុន** ជាអគ្គលេខាធិការរងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះ រាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៥ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស.រកត.០៨៩៧.១៦៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត /០៥៩៦/២០ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៦
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តម្លើងឋានៈឯកឧត្តមបណ្ឌិត **ខែម វិឡាំ** អគ្គលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ស្មើ រដ្ឋលេខាធិការ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស /រកត/០៨៩៧/១៦៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត /០៥៩៦/២០ ចុះថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៩៦
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងលោក **ខៀង សេងឆ្លួន** ប្រធាននាយកដ្ឋានបុគ្គលិក ជាអគ្គលេខាធិការរង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ នស /រកត/០៨៩៧/១៩៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **គង់. ឆាន** ជាអនុប្រធានទី១ យុវនីតិសម្បទា មានបុព្វសិទ្ធិស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ នស /រកត/០៨៩៧/១៩៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ខែ សីហា ឆ្នាំ ១៩៩៧

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ទៅ សាមី** ជាអនុប្រធានទី២ យុវនីតិសម្បទា មានបុព្វសិទ្ធិស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២.- នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសម្រេច ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់តាំងពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស /រកត/០៨៩៧/១៩៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/៩៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញលិខិតលេខ ១០១ សរ. ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុម័តលើកអភ័យឯកសិទ្ធិសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីនាយករដ្ឋមន្ត្រីទាំងពីរ

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **អ៊ុង ហួត** នាយករដ្ឋមន្ត្រីទី ១ ឱ្យទទួលភារកិច្ចជាសហប្រធានគណៈកម្មាធិការជាតិ ក្រុមប្រឹក្សាជាតិ និងគណៈកម្មាធិការនានាទាំងអស់ ជំនួស សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចេញផ្សាយកន្លងមក ។

មាត្រា ២.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស /រកត/០៨៩៧/១៩៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល កម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការ រៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/៩៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីនាយករដ្ឋមន្ត្រីទាំងពីរ

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ហេង ធន្យាម៉ុននារត** ជាឧត្តមទីប្រឹក្សារបស់រាជរដ្ឋាភិបាល មាន ឋានៈស្មើនឹងទេសរដ្ឋមន្ត្រី ។

មាត្រា ២.- ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

***

ព្រះរាជក្រឹត្យ ជស /រកត/០៨៩៧/១៩៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/៩៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីនាយករដ្ឋមន្ត្រីទាំងពីរ

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **សុន គន្ធរ** ជាទីប្រឹក្សារបស់រាជរដ្ឋាភិបាល ទទួលបន្ទុកសេដ្ឋកិច្ច កសិកម្ម និងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើនឹងរដ្ឋលេខាធិការ ។

មាត្រា ២ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៩៧

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

KRET/ NS/KRT/0897/60

Nous

NORODOM SIHANOUK

ROI du CAMBODGE

nommons

Monsieur KYLE GILLESPLE

Officier de l'Ordre Royal du SAHAMETREI

Fait le 28 Août 1997

Signé

NORODOM SIHANOUK

***

II- រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

អនុក្រឹត្យលេខ ៤៤ អនក្រ .បក

ស្តីពីការផ្ទេរឥណទាន

***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជ ក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃ ទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃ ទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើដោយព្រះ រាជក្រម លេខ នស/រកម/១២៩៦/៣៧ ចុះថ្ងៃ ទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៦
-បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃ ទី ២៧ ខែ មករា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែក ឥណទានផ្ទៃក្នុងជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៧
-បានឃើញប្រកាសលេខ ០១ ប្រ .សហវ ចុះថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីចំណាត់ថ្នាក់ ចំណូល និង ចំណាយថវិកាតាមប្រភេទជំពូក ប្រការកថាខណ្ឌ វាក្យខណ្ឌ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៤ និង ប្រកាសស្តីពីការកែប្រែ និង បំពេញបន្ថែមជាបន្តបន្ទាប់មាន: លេខ ០២២ ប្រ. សហវ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៩៤ លេខ ០៣ ប្រ. សហវ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ . លេខ ៣២៣ ប្រក.សហវ.ថ ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៥. លេខ ៣៣៦ ប្រក.សហវ .ថ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៥. លេខ ០៧១ ប្រក. សហវ.ថ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៦ និង លេខ ៨០១ សហវ.ថ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី និង ជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ .

សំរេច

មាត្រា ១.- ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានពី ជំពូក ២០ (ការប្រាក់នៃការខ្ចីបុលរយៈពេល វែង មធ្យម ខ្លី) ចំនួន ១.៥០០ លានរៀល និង ជំពូក ៤១ (ចំណាយឥតគ្រោងទុក) ចំនួន ២.០០០ លានរៀល (ពីរពាន់លានរៀល) របស់រាជរដ្ឋាភិបាល មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច) ក្នុងរង្វង់ថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រីសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ២.- ត្រូវបានអនុញ្ញាត ឱ្យផ្ទេរឥណទាន ពីជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌) ចំនួន៥០០លានរៀល (ប្រាំរយលានរៀល) របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មកជំពូក ៣១ (អន្តរាគមន៍ ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌) ក្នុងរង្វង់ថវិកា របស់ទីស្តីការគណៈ រដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧ ។

មាត្រា ៣.- ឥណទានក្នុងមាត្រា ១ និងមាត្រា ២ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ សំរាប់បំពេញតម្រូវការជូនរាជរដ្ឋាភិបាល ។

មាត្រា ៤.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានី ភ្នំពេញ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ១៩៩៧

ហត្ថលេខា និង ត្រា

នាយករដ្ឋមន្ត្រី ទី ១ នាយករដ្ឋមន្ត្រី ទី ២

អ៊ុង ហួត ហ៊ុន សែន

***

អនុក្រឹត្យ លេខ ៤៥ អនក្រ បក

ស្តីពីការរំសាយ និងការបង្កើតទីស្នាក់ការត្រួតពិនិត្យតាមច្រកព្រំដែន និង ផ្លូវគមនាគមន៍នៅទូទាំងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /១០៩៤ /៩៣ ចុះថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសភាពការណ៍ចាំបាច់

សំរេច

មាត្រា ១.- ត្រូវបានរំសាយទីស្នាក់ការត្រួតពិនិត្យ ដែលបានបង្កើតកន្លងមកទាំងអស់ ស្ថិតនៅតាមច្រកព្រំដែន និង ផ្លូវគមនាគមន៍ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.- ត្រូវបានបង្កើតឡើងវិញនូវទីស្នាក់ការត្រួតពិនិត្យតាមច្រកចេញ-ចូលនៅព្រំដែន និងនៅតាមផ្លូវគមនាគមន៍ ជាអាទិ៍ ផ្លូវគោក ផ្លូវទឹក ផ្លូវដែក ផ្លូវអាកាស នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ស្ថិតក្រោមការគ្រប់គ្រងរបស់ថ្នាក់កណ្តាល មានដូចខាង ក្រោម ។

ក.-អំពីផ្លូវជាតិ:

១-ផ្លូវជាតិលេខ១ ពីព្រំដែនបាវិត មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : បាវិត(ខេត្តស្វាយរៀង) ។

២- ផ្លូវជាតិលេខ២ ពីព្រំដែនភ្នំដិន មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច: ភ្នំដិន (ខេត្តតាកែវ)

៣- ផ្លូវជាតិលេខ ៤ ពីក្រុងព្រះសីហនុ មកដល់រាជធានីភ្នំពេញមាន ០២ ចំណុច : កំពង់ផែក្រុងព្រះសីហនុ និងកណ្តាលក្តិ (ខេត្តកំពង់ស្ពឺ)

៤-ផ្លូវជាតិលេខ ៥ ពីព្រំដែនប៉ោយប៉ែត មកដល់រាជធានីភ្នំពេញមាន ០២ ចំណុច: ប៉ោយប៉ែត និងទឹកថ្លា (ខេត្តបន្ទាយមានជ័យ)

ខ.-អំពីផ្លូវទឹក:

១- តាមដងទន្លេមេគង្គលើពីព្រំដែនប្រទេសឡាវ មកដល់រាជធានីភ្នំពេញមាន ០១ចំណុច : អូរស្វាយ-កោះឈើទាលធំ (ខេត្តស្ទឹងត្រែង) ។

២- តាមដងទន្លេមេគង្គក្រោម ពីព្រំដែនប្រទេសវៀតណាម មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច: កោះរការ-ក្អមសំណរ ។

៣- តាមដងទន្លេបាសាក់ ពីព្រំដែនប្រទេសវៀតណាម មកដល់រាជធានីភ្នំពេញមាន ០១ ចំណុច : ខ្ពង់តាំងយូ-ជ្រៃធំ ។

៤- នៅរាជធានីភ្នំពេញមានកំពង់ផែពាណិជ្ជកម្មអន្តរជាតិទីក្រុងភ្នំពេញ ។

គ.- អំពីផ្លូវដែក :

- ផ្លូវដែកទាំងពីរទិសមាន ០៥ ចំណុច : ស្ថានីយ៍រាជាយស្ម័យានកម្ពុជា (ភ្នំពេញ) ស្ថានីយ៍រថភ្លើងក្រុងព្រះសីហនុ ស្ថានីយ៍រថភ្លើង ទីរួមខេត្តពោធិសាត់ ស្ថានីយ៍រថភ្លើងទីរួមខេត្តបាត់ដំបង និងស្ថានីយ៍រថភ្លើងខេត្តបន្ទាយមានជ័យ ។

ឃ.- អំពីផ្លូវសមុទ្រ :

១- ខេត្តកោះកុងមាន ៥ចំណុច : កោះស្តេច ប៉ាក់ខ្លង ថ្មស ចាំយាម និងស្រែអំបិល ។

២- ក្រុងព្រះសីហនុមាន ៣ចំណុច : កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ ទំនប់រលក និង ស្ទឹងហាវ

៣- ខេត្តកំពតមាន ៤ចំណុច : ទាន់ហាន់ កោះសេះ ត្រពាំងល្ពៅ និងផែ ទីរួមខេត្តកំពត ។

៤- ទីក្រុងកែបមាន ១ចំណុច : ផែក្រុងកែប ។

ខ- អំពីផ្លូវអាកាស :

-ផ្លូវអាកាសមាន ០៨ចំណុច: អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង អាកាសយានស្ថាន កងកេងក្រុងព្រះសីហនុ, ខេត្តសៀមរាប, ទីរួមខេត្តកោះកុង, វាលបែកចានទីរួមខេត្តបាត់ដំបង, ទីរួមខេត្តស្ទឹងត្រែង, បានលុងទីរួមខេត្តរតនគីរី និងអាកាសយានដ្ឋានខេត្តមណ្ឌលគីរី ។

មាត្រា ៣.- ត្រូវបានកំណត់ និង បង្កើតទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ និងច្រកទ្វារចេញ ចូល-ព្រំដែនប្រទេសមានដូចខាងក្រោម :

១ - ច្រកទ្វារព្រំដែនអន្តរជាតិ :

- រាជធានីភ្នំពេញ :

១- អាកាសយានដ្ឋានអន្តរជាតិពោធិចិនតុង

២- កំពង់ផែពាណិជ្ជកម្មអន្តរជាតិរាជធានីភ្នំពេញ

- ក្រុងព្រះសីហនុ :

៣- កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ

- ខេត្តស្វាយរៀង :

៤- បាវិត (លើផ្លូវជាតិលេខ ១)

- ខេត្តកណ្តាល-ព្រៃវែង :

៥- ក្អមសំណរ-កោះរការ (ទន្លេមេគង្គ)

- ខេត្តតាកែវ:

៦- ភ្នំដិន (លើផ្លូវជាតិលេខ២)

- ខេត្តកោះកុង:

៧- ចាំយាម

- ខេត្តបន្ទាយមានជ័យ :

៨- ប៉ោយប៉ែត

២- ច្រកទ្វារព្រំដែនចេញ-ចូលប្រទេសទេសចរណ៍ :

- ខេត្តរតនគិរី :

១- អូរយ៉ាដាវ (លើផ្លូវជាតិលេខ ១៩)

- ខេត្តមណ្ឌលគិរី :

២- ដាក់ដាំ (លើផ្លូវជាតិលេខ ១៤)

- ខេត្តក្រចេះ :

៣- ស្នួល (លើផ្លូវជាតិលេខ ១៣)

- ខេត្តកំពង់ចាម :

៤- ត្រពាំងផ្លុង (លើផ្លូវជាតិលេខ ៧)

- ខេត្តកំពត :

៥- ព្រែកចាក (លើផ្លូវជាតិលេខ ១៧)

៣- ច្រកទ្វារតំបន់ព្រំដែន :

- ខេត្តមណ្ឌលគិរី :

១- បាឡាខេ (ផ្លូវគោក)

- ខេត្តក្រចេះ :

២- ជ័យឃ្លាំង

៣- វ៉ាលី

- ខេត្តកំពង់ចាម :

៤-មេមត់ (ផ្លូវគោក)

៥- ដា (ផ្លូវគោក)

៦- ដាំក្រវៀន (ផ្លូវគោក)

- ខេត្តព្រៃវែង :

៧- ពាមមន្ទា (ផ្លូវទឹក)

៨- កោះសំពៅ (ផ្លូវទឹក)

- ខេត្តស្វាយរៀង :

៩- បុសមន (ផ្លូវគោក)

១០- ព្រៃវល្លិ (ផ្លូវគោក)

១១-សំរោង (ផ្លូវគោក)

- **ខេត្តកណ្ដាល :**

១២ - ព្រែធំ -ខ្លាតាំងយូរ (ផ្លូវទឹក)

- **ខេត្តតាកែវ :**

១៣ - បាក់ដៃ (ផ្លូវទឹក)

១៤-កំពង់ក្រសាំង (ផ្លូវទឹក)

- **ខេត្តកំពត :**

១៥ - ទាន់ហាន់ (ផ្លូវសមុទ្រ)

១៦- កោះសេះ (ផ្លូវសមុទ្រ)

១៧- ត្រពាំងល្ពៅ (ផ្លូវសមុទ្រ)

១៨- ទីរួមខេត្ត (ផែ)

- **ទីក្រុងកែប :**

១៩- ផែទីក្រុងកែប

- **ក្រុងព្រះសីហនុ :**

២០- ទំនប់រលក (ផែ)

២១- ស្ទឹងហាវ

- **ខេត្តកោះកុង :**

២២- កោះស្ដេច (ផែ)

២៣- ប៉ាក់ខ្លង (ផែ)

២៤- ថ្មស

២៥- ស្រែអំបិល

- **ខេត្តពោធិ៍សាត់ :**

២៦- ភ្នំឬស្សី

២៧- ស្ពានជ័យជំនះ (វាលវែង)

២៨- ប្រកផ្លូវ ៥៦ (វាលវែង)

- **ខេត្តបន្ទាយមានជ័យ :**

២៩- បឹងត្រកួន

៣០- មៅឡៃ

- **ខេត្តឧត្តរមានជ័យ :**

៣១- អូរស្មាច់(ផ្លូវគោក)

- **ខេត្តព្រះវិហារ :**

៣២- អានសេះ

- **ខេត្តបាត់ដំបង :**

៣៣- ភ្នំដី

៣៤- សួនស៊ី (កំរៀង)

៣៥- ប៉ៃលិន

៣៦- ច្រក ៤០០ (សំឡូត)

៣៧- ច្រក ២០៣ (សំឡូត)

៣៨-ពាមតា (សំឡូត)

៣៩- បានសានឆាវ (សំឡូត)

៤០- ភ្នំព្រឹក (សំពៅលូន)

៤១-ស្វាយចេក (កំរៀង)

៤២- អូររំដួល (កំរៀង)

- **ខេត្តស្ទឹងត្រែង :**

៤៣- អូរស្វាយ-កោះឈើទាលធំ (ផ្លូវទឹក)

៤៤- ដុងក្រឡ (ផ្លូវគោក)

មាត្រា ៤.- សមាសភាព តួនាទី និងភារកិច្ច របស់កងកម្លាំងប្រដាប់អាវុធ និងភ្នាក់ងារមានសមត្ថកិច្ចប្រចាំការ នៅតាមទីស្នាក់ការ ត្រួតពិនិត្យមានដូចខាងក្រោម :

ក- អំពីសមាសភាព

ក១ - នៅតាមច្រកឡរព្រំដែនអន្តរជាតិ :

១- មន្ត្រីរដ្ឋបាល មានឋានៈស្មើអនុប្រធាននាយកដ្ឋាន ប្រធាន

២- កំលាំងនគរបាលជាតិ ផ្នែកអន្តោប្រវេសន៍ សមាជិក

៣- ភ្នាក់ងារកាំកុងត្រូល សមាជិក

៤- ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

៥- ភ្នាក់ងារភូតគាមអនាម័យ សមាជិក

៦- ភ្នាក់ងារចត្តាឡីសក្តិ សមាជិក

៧- ភ្នាក់ងារត្រួតពិនិត្យឱសថ សមាជិក

ដោយឡែកនៅតាម :

- អាកាសយានដ្ឋានអន្តរជាតិ មានអាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន ។
- កំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ និងទីក្រុងភ្នំពេញមាន ប្រធានមណ្ឌលកំពង់ផែជាប្រធាន និងកាំសាបជាសមាជិកថែមទៀត ។

គ២. នៅតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារតំបន់ព្រំដែន និង ច្រកទ្វារព្រំដែនចេញចូល ប្រទេសទ្វេភាគីកម្ពុជា-ឡាវ.កម្ពុជា-វៀតណាម និងកម្ពុជា-ថៃ :

១-កំលាំងនគរបាលជាតិ ផ្នែកអន្តោប្រវេសន៍ ជាប្រធាន

២-ភ្នាក់ងារកាំកុងត្រូល សមាជិក

៣-ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

គ៣. នៅតាមទីស្នាក់ការត្រួតពិនិត្យតាមផ្លូវគោកផ្ទៃក្នុងប្រទេស :

១- ភ្នាក់ងារគយនិងរដ្ឋាករ

គ៤. នៅតាមអាកាសយានដ្ឋានផ្ទៃក្នុងប្រទេស :

១- អាជ្ញាធរអាកាសចរស៊ីវិល ជាប្រធាន

២-កំលាំងនគរបាលជាតិ សមាជិក

៣- ភ្នាក់ងារគយ និងរដ្ឋាករ សមាជិក

ខ. អំពីតួនាទីភារកិច្ចនៃទីស្នាក់ការត្រួតពិនិត្យ និង កំលាំងត្រួតពិនិត្យនៅតាមទីស្នាក់ការត្រួតពិនិត្យ នីមួយៗ :

១១.ទីស្នាក់ការត្រួតពិនិត្យនីមួយៗ ត្រូវធានាអោយបានល្អ :

កិច្ចថែរក្សាការពារអធិបតេយ្យភាព បូរណភាពទឹកដី និង ការអនុវត្តន៍ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា

+ កិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម

+ គ្រប់គ្រងសេដ្ឋកិច្ច និងសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរដែនដី

+ សំរួលចរាចរដឹកជញ្ជូន ការធ្វើដំណើរទៅមករបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេស

+ រកឱ្យ ឃើញ ទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលា រាល់បទល្មើសច្បាប់នានា ពិសេសបទល្មើសព្រំដែន ។

+ ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងស្ថាប័នជំនាញសាមី និងចម្លងជូនអភិបាលខេត្តក្រុង ។

១២. តួនាទី ភារកិច្ច និង សិទ្ធិអំណាចរបស់គងកំលាំងនគរបាលជាតិផ្នែកអន្តោប្រវេសន៍ និងភ្នាក់ងារជំនាញមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវអនុវត្តតាមច្បាប់ និងលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល និង ប្រកាស សារាចរ របស់ក្រសួងសាមី មានជាអាទិ៍ ដូចខាងក្រោម :

១-កំលាំងនគរបាលជាតិផ្នែកអន្តោប្រវេសន៍ទទួលបន្ទុកគ្រប់គ្រង និងត្រួតពិនិត្យការចេញ - ចូល ឆ្លងកាត់ព្រំដែន ត្រួតពិនិត្យការងារចរាចរ ការធ្វើដំណើរទៅមករបស់ជនបរទេស និងជនស៊ីវិលជាប្រជាពលរដ្ឋខ្មែរ បង្ក្រាបបានទាន់ពេលវេលាបទល្មើសឆ្លងដែន និង បទល្មើសផ្សេងៗ រួមជាមួយកំលាំងមានសមត្ថកិច្ចផែកឯទៀតអាវុធជាតិផ្ទុះ សំដៅរក្សាសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋាននគរបាលជាតិ និងជូនប្រធានទីស្នាក់ការ ។

២- ភ្នាក់ងារកាំកុងត្រូលទទួលត្រួតពិនិត្យលើបរិមាណ ទម្ងន់ គុណភាព សភាពផលិតផលនៃទំនិញ នាំចេញ-ចូលព្រមទាំងចេញវិញ្ញាបនប័ត្រលើបរិមាណ ទម្ងន់ គុណភាព និងសភាពផលិតផល នៃទំនិញនាំចេញ-នាំចូល ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងពាណិជ្ជកម្ម និងប្រធានទីស្នាក់ការ ។

៣-ភ្នាក់ងារគយនិងរដ្ឋាករសហការជាមួយភ្នាក់ងារជំនាញ នៃក្រសួងស្ថាប័នដែលឈរប្រចាំការ នៅទីស្នាក់ការត្រួតពិនិត្យ ទទួលបន្ទុកក្នុងការត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ទំនិញ ឥវ៉ាន់ អ្នកដំណើរ កញ្ចប់ ឬ ហិបផ្ញើតាមប្រៃសណីយ៍ រូបិយវត្ថុ -លោហធាតុត្បូងថ្មមានតម្លៃ ថ្នាំពុល អាវុធ ដើម្បីធ្វើការប្រមូលពន្ធនាំចេញ-នាំចូល និងពន្ធផ្សេងៗ ព្រមទាំងទប់ស្កាត់ និងបង្ក្រាបអំពើរត់ពន្ធ និងអំពើវិច្ឆេទកម្មសេដ្ឋកិច្ច ។ល។

-អនុវត្តតាមខ្លឹមសារនៃសារាចរលេខ ០០១ សរ.សហវ.គវ ចុះថ្ងៃ ទី ០៦ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការគ្រប់គ្រងមន្ត្រីគយ និងរដ្ឋាកររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

- ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ អំពីសកម្មភាពការងាររបស់ខ្លួន ជូនក្រសួង សេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងប្រធានទីស្នាក់ការ ។

៤- ភ្នាក់ងារភូតគាមអនាម័យត្រួតពិនិត្យផលិតផល និង ទំនិញមានដើមកំណើតពីរុក្ខជាតិ និងត្រួតពិនិត្យសត្វគ្រប់ប្រភេទ ដែលធ្វើការនាំចេញ និងនាំចូល ។

- អនុវត្តតាមប្រកាសណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

-ធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួងកសិកម្ម រុក្ខារ ប្រមាញ់ និងនេសាទ និងប្រធានទីស្នាក់ការ ។

៥-ភ្នាក់ងារត្រួតពិនិត្យឱសថ ទទួលត្រួតពិនិត្យបែបបទនាំចូល-នាំចេញផលិតផលឱសថ វិញ្ញាបនប័ត្រនាំចូល នាំចេញផលិតផលឱសថនិងត្រួតពិនិត្យគុណភាពឱសថ ។

៦- ចត្តាឡីស័ក្តិទទួលបន្ទុកត្រួតពិនិត្យលើវិញ្ញាបនប័ត្រសុខភាពមនុស្ស និង លក្ខណៈអនាម័យ នៃមធ្យោបាយដឹកជញ្ជូនចេញ-ចូល ឆ្លងកាត់ព្រំដែន ។

-ភ្នាក់ងារត្រួត ពិនិត្យឱសថនិងចត្តាឡីសក្តិ ត្រូវធ្វើរបាយការណ៍ប្រចាំខែយ៉ាងទៀងទាត់ជូនក្រសួងសុខាភិបាល និងប្រធានទីស្នាក់ការ ។

មាត្រា ៥.- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវរៀបចំសាងសង់ទីស្នាក់ការឱ្យបានរឹងមាំល្អសមស្របតាមសំណង់វប្បធម៌ជាតិ ងាយស្រួលក្នុងការត្រួតពិនិត្យ និងធានាបានការលើក តំកើងមុខមាត់នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៦.- ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល ១ ឆ្នាំម្តងហើយ បើសិនបំពេញការងារបានល្អប្រសើរជូនប្រទេសជាតិ គឺអាចពន្យារពេលបំរើការងារបានម្តងគត់ស្មើនឹង ១ ឆ្នាំទៀត ។

មាត្រា ៧.- ភ្នាក់ងារមានសមត្ថកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យ ត្រូវមានវត្តមានអនុវត្តភារកិច្ចរបស់ខ្លួន នៅកន្លែងមួយជាកំណត់ (ONE WAY ONE STOP) ដើម្បីសំរួលការងារ បំពេញបែបបទដល់អតិថិជន ដែលនាំទំនិញឆ្លងកាត់ឱ្យបានឆាប់ ។

មាត្រា ៨.- ភ្នាក់ងារមានសមត្ថកិច្ចនៅតាមទីស្នាក់ការត្រួតពិនិត្យ ហើយបែរជាឆ្លៀតប្រើប្រាស់តួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន បង្កអោយមានការលំបាកស្មុគ្រស្មាញ ដល់ការធ្វើដំណើររបស់ប្រជាពលរដ្ឋខ្មែរ ជនបរទេស ភ្ញៀវទេសចរណ៍ ឬ បង្កឱ្យមានការយឺតយ៉ាវ ដែលគ្មានមូលហេតុដល់ការនាំចេញ-នាំចូល ការដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម និងផលិតផលផ្សេងៗ របស់ក្រុមហ៊ុន ឬ ឯកជន និងធ្វើឱ្យមានការរាំងស្ទះក្នុងការប្រមូលពន្ធ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ៩.- ភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ ត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ និងយ៉ាងសកម្មប្រកបដោយអាកប្បកិរិយាសុភាពរាបសារ ជៀសវាងបាននូវ ការប៉ះទង្គិចខាងសតិអារម្មណ៍ ចំពោះប្រជាពលរដ្ឋ អ្នកធ្វើដំណើរទូទៅ ដោយគ្មានមូលហេតុសមស្រប ។

មាត្រា ១០.- ភ្នាក់ងារមានសមត្ថកិច្ច ដែលប្រចាំការនៅទីស្នាក់ការត្រួតពិនិត្យ លើកលែងតែភ្នាក់ងារគយ និងរដ្ឋាករ ក្រសួងស្ថាប័នសាមីត្រូវធ្វើការផ្លាស់ប្តូរក្នុងរយៈពេល០៦ខែម្តង និងត្រូវធ្វើបញ្ជីរាយនាមភ្នាក់ងារមានសមត្ថកិច្ចទាំងនោះមក ទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់លើកផ្លាស់ប្តូរម្តងៗ ។ បើភ្នាក់ងារណាបំពេញការងារបានល្អប្រសើរជូនប្រទេសជាតិ គឺត្រូវអាចពន្យារពេលបានម្តងគត់ស្មើនឹង ០៦ ខែទៀត ។

មាត្រា ១១.- ក្រុម ឬ ជនប្រដាប់អាវុធ ដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យ បង្កឱ្យមានការយឺតយ៉ាវដល់ការធ្វើដំណើរការដឹកជញ្ជូនទំនិញ សំភារៈ វត្ថុធាតុដើម ឬ បាត់បង់ទ្រព្យសម្បត្តិ អាយុជីវិតរបស់ប្រជាពលរដ្ឋខ្មែរ និងជនបរទេស ត្រូវធ្វើការដកហូតមុខងារ ឬ ពិន័យផ្នែករដ្ឋបាល ឬ បញ្ជូនខ្លួនទៅតុលាការ ដើម្បីផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

មាត្រា ១២.- អភិបាលខេត្ត-ក្រុងសាមីតំណាងឱ្យរាជរដ្ឋាភិបាល ក្នុងការដោះស្រាយនូវបញ្ហាផ្ទៃក្នុងរបស់ទីស្នាក់ការត្រួតពិនិត្យ និងសំរបសំរួលដល់ការងារដើម្បីធ្វើឱ្យទីស្នាក់ការ ត្រួតពិនិត្យមានដំណើរការល្អទៅតាមស្របតាមសំណូមពរអតិថិជន និងធានាក្នុងការអនុវត្តន៍ច្បាប់នានា។ ក្រៅពីនេះ ត្រូវទទួលខុសត្រូវក្នុងការបង្ក្រាបនិងលុបបំបាត់កំលាំងដែលបង្កើតទីស្នាក់ការត្រួតពិនិត្យអនាធិបតេយ្យក្នុងដែនដីដែលខ្លួនគ្រប់គ្រង ។

-ក្នុងករណីកំលាំងអនាធិបតេយ្យនៅតែបង្កើតទីស្នាក់ការត្រួតពិនិត្យចល័ត ផ្ទុយពីខ្លឹមសារអនុក្រឹត្យនេះ រាជរដ្ឋាភិបាលនឹងដកហូតមុខងាររបស់អភិបាលស្រុក-ខ័ណ្ឌសាមី ឬក្នុងករណីធ្ងន់ធ្ងរ អាចដកហូតមុខងាររបស់អភិបាលខេត្ត-ក្រុងសាមី តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

-ដោយឡែក នៅកំពង់ផែពាណិជ្ជកម្មអន្តរជាតិក្រុងព្រះសីហនុ អាជ្ញាធរក្រុងព្រះសីហនុ ត្រូវទទួលបន្ទុកដោះស្រាយរាល់បញ្ហានិងបាតុភាពផ្សេងៗ ដែលកើតមានឡើង ដើម្បីសម្របសម្រួលការងារ ឱ្យមានភាពជឿនលឿន និងឆាប់រហ័ស ។

មាត្រា ១៣.- ក្រុមគយ និងរដ្ឋាករចល័ត ដែលស្ថិតក្រោមការដឹកនាំផ្ទាល់របស់នាយកទីចាត់ការគយ និងរដ្ឋាករ មានភារកិច្ចធ្វើការស្រាវជ្រាវ និងបង្ក្រាបអំពើរត់គេចពន្ធពីច្រកទ្វារព្រំដែនចូលមកផ្ទៃក្នុងប្រទេស ។

-ក្រុមគយនិងរដ្ឋាករចល័តនេះ អាចចេញធ្វើប្រតិបត្តិការឃាត់តាម មធ្យោបាយដឹកទំនិញបានក្នុងពេលណាដែលទទួលពិតមានថា មធ្យោបាយដឹកទំនិញនោះ កំពុងប្រព្រឹត្តអំពើរត់គេចពន្ធពីព្រំដែនចូលមកផ្ទៃក្នុងប្រទេស និងមានបញ្ជាបេសកកម្មពី នាយកទីចាត់ការគយនិងរដ្ឋាករ តាមករណីជាក់ស្តែងនីមួយៗ មិនអនុញ្ញាតឱ្យក្រុមគយ និង រដ្ឋាករចល័តនេះធ្វើសកម្មភាពបែបអនាធិបតេយ្យឡើយ ។

មាត្រា ១៤.- ក្រសួង ស្ថាប័នសាមីដែលមានកម្លាំងនៅតាមទីស្នាក់ការត្រួតពិនិត្យដែលចែងក្នុងអនុក្រឹត្យនេះ ត្រូវសហការជាមួយអភិបាលខេត្ត-ក្រុង ដើម្បីធ្វើអធិការកិច្ចជាប់ជាប្រចាំនៅលើទីស្នាក់ការត្រួតពិនិត្យ និងត្រូវរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនមកទីស្តីការគណៈរដ្ឋមន្ត្រីរៀង រាល់ខែ ។

មាត្រា ១៥.- អនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ និងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៦.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូរាជរដ្ឋាភិបាលប្រចាំ រាជធានីភ្នំពេញ ប្រចាំក្រុងកែប ប្រចាំក្រុងប៉ៃលិន និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ ទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហ៊ួត **ហ៊ុន សែន**

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧

សេចក្តីសំរេច លេខ ២៩ សសរ

ស្តីពី

ការផ្គត់ផ្គង់ប្រេងឥន្ធនៈជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និង ក្រុមហ៊ុនវិនិយោគនានា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃ ទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃ ទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- ផ្អែកលើបទពិសោធន៍ល្អនៃការងារផ្គត់ផ្គង់ប្រេងឥន្ធនៈរបស់ក្រុមហ៊ុន សូគីម៉ិច កន្លងមក
- ក្នុងគោលដៅអនុវត្តគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនឯកជនក្នុងស្រុក
- យោងតាមការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី ១ ចុះថ្ងៃទី ២១ សីហា ឆ្នាំ ១៩៩៧ និងការយល់ព្រមរបស់នាយករដ្ឋមន្ត្រីទី ២ ចុះ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១.- អនុញ្ញាតនិងប្រគល់សិទ្ធិឱ្យក្រុមហ៊ុនសូគីម៉ិច ក្នុងការធានាផ្គត់ផ្គង់ប្រេងឥន្ធនៈ ជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ក្រុមហ៊ុនអគ្គិសនីកម្ពុជា បណ្តាក្រុមហ៊ុនចំការកៅស៊ូ កំពង់ផែពាណិជ្ជកម្មអន្តរជាតិ អាកាសយានដ្ឋានអន្តរជាតិ ស្ថាប័ន និងក្រុមហ៊ុនវិនិយោគនានា ។

- ក្នុងករណីក្រុមហ៊ុនសូគីម៉ិច អស់លទ្ធភាពក្នុងការផ្គត់ផ្គង់ប្រេងឥន្ធនៈ នោះបណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងអង្គភាពរដ្ឋ មានសិទ្ធិទាក់ទងជាមួយក្រុមហ៊ុនផ្សេងទៀត ដើម្បីផ្គត់ផ្គង់ជូនតាមសមត្ថភាព ជាក់ស្តែង ។

ប្រការ ២.- ចំពោះថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈដែលមានចែងក្នុងប្រការ១ នេះ ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័ននានា រួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិគ្រោះថ្លៃជាមួយក្រុមហ៊ុនសូគីម៉ិច តាមតំណាក់កាលនីមួយៗ ជាបន្តបន្ទាប់ឱ្យបានត្រឹមត្រូវ ។

ប្រការ ៣.- ចំពោះការផ្គត់ផ្គង់ប្រេងឥន្ធនៈឱ្យក្រុមហ៊ុនវិនិយោគនានា ក្រុមហ៊ុនសូគីម៉ិចត្រូវសុំការព្រមព្រៀងគ្នារវាងក្រុមហ៊ុននិងក្រុមហ៊ុន ព្រមទាំងមានការពិគ្រោះតាមសភាពជាក់ស្តែងនៃទីផ្សារ និងមានការ ប្រកួតប្រជែង ។

ប្រការ ៤.- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥.- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃបណ្ដាក្រសួង រដ្ឋលេខាធិការដ្ឋានស្ថាប័ន ក្រុមហ៊ុនសូគីម៉ិច និងក្រុមហ៊ុនវិនិយោគនានា ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត **ហ៊ុន សែន**

***

៣. សារាចរ

រាជធានីភ្នំពេញ ថ្ងៃ ទី ២៧ ខែ សីហា ឆ្នាំ ១៩៩៧

សារាចរលេខ ០៦ ស.រ ស្ដីពីការគិតគូរពីង កិច្ចការរៀបចំបរិយាកាសនយោបាយអព្យាក្រឹត និង សន្តិសុខសាធារណៈ

ព្រឹត្តិការណ៍ដ៏ជូរចត់កាលពីថ្ងៃទី ០៥-០៦ កក្កដា ១៩៩៧ បានផ្ដល់មេរៀនពិសោធន៍យ៉ាងច្រើនដល់ប្រជាជនកម្ពុជា ដល់គណបក្សនយោបាយ និងអ្នកនយោបាយនៅកម្ពុជាថា ល្បែងប្រជាធិបតេយ្យដែលគ្មានសិលធម៌ ហើយរំលោភច្បាប់ដោយចេតនា ការក្បត់គ្នាខាងនយោបាយ ការស្វែងរកតុល្យភាពកំលាំងយោធា ដើម្បីទ្រទ្រង់ឱ្យសកម្មភាពនយោបាយរបស់គណបក្ស ដោយបោះបង់ចោលគោលការណ៍អព្យាក្រឹតូបនីយកម្មខាងនយោបាយ ចំពោះកំលាំងប្រដាប់អាវុធ និងរដ្ឋបាលស៊ីវិលគឺជាផ្លូវដ៏គ្រោះថ្នាក់ ។ វាមិនគ្រាន់តែមិនអាចប្រកួតប្រជែងតាមផ្លូវប្រជាធិបតេយ្យសំរាប់ស្ថានភាពប្រជាធិបតេយ្យសេរីពហុបក្សបានប៉ុណ្ណោះទេ ប៉ុន្តែវានៅបង្កើតបានជាការគំរាមកំហែងសន្តិសុខជាតិ រហូតមានសង្គ្រាមបង្ហូរឈាមទៀតផង ។

នៅកម្ពុជា ទោះត្រូវជួបប្រទះនូវគ្រោះថ្នាក់ បង្កឡើងដោយក្រុមនិយមជ្រុលឃុបឃិតជាមួយខ្មែរក្រហមក្រៅច្បាប់កាលពីខែកក្កដា១៩៩៧ កន្លងទៅក៏ដោយ ក៏យើងបាននិងកំពុងប្ដេជ្ញា រក្សានូវសមិទ្ធផលនៃកិច្ចព្រមព្រៀងក្រុងប៉ារីសគឺលទ្ធផលនៃការបោះឆ្នោត ឆ្នាំ១៩៩៣ ដោយរក្សា និងអនុវត្តនូវរដ្ឋធម្មនុញ្ញ និរន្តរភាពរបស់រដ្ឋសភា រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ព្រះ

មហាក្សត្រ ។ ដំណើរឆ្ពោះទៅមុខរបស់យើង មិនគ្រាន់តែដើម្បីបំរើអោយ ការបោះឆ្នោតខែ ឧសភា ១៩៩៨ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវធានានូវដំណើរការជានីតិរដ្ឋ ក្នុងស្ថានភាពប្រជាធិបតេយ្យ សេរីពហុបក្ស ។ ដូចនេះ ភារកិច្ចធំៗជាយុទ្ធសាស្ត្រ ទាំងចំពោះមុខ និង យូរអង្វែង ត្រូវកំណត់ លើអាទិភាព ៣ គឺ :

១- ស្ថេរភាពខាងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បរិយាកាសនយោបាយ អព្យាក្រឹត សំរាប់ការបោះឆ្នោត ។

២- រក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា រក្សាល្បឿនកំណើនខាងសេដ្ឋកិច្ច ។

៣- បន្តកែទំរង់ខាងសេដ្ឋកិច្ច រដ្ឋបាលនិងកងទ័ព ....

ភារកិច្ចយុទ្ធសាស្ត្រធំៗទាំងបីនេះ ត្រូវអនុវត្តព្រមៗគ្នាជាចង្វាក់តែមួយ នៃចំណងមួយ ដើម្បីធានាឱ្យកម្ពុជាដើរលើផ្លូវស្ថេរភាពខាងនយោបាយ ប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស ការបង្រួបបង្រួមជាតិ និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដោយភាពប្រាកដនិយម ។

ក្រោយព្រឹត្តិការណ៍ ខែកក្កដា ១៩៩៧ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាធ្វើការបោះឆ្នោត ជាសាកល នៅខែ ឧសភា ឆ្នាំ ១៩៩៨ ។ ដូចនេះ ទន្ទឹមនឹងរដ្ឋសភាធ្វើការអនុម័តច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ច្បាប់ស្តីពីគណបក្សនយោបាយ រាជរដ្ឋាភិបាលក៏ដូចជា អគ្គបញ្ជាការដ្ឋាននៃកងកម្លាំងប្រដាប់អាវុធជាតិកម្ពុជា ឆ្លងតាមស្ថាប័នក្រសួងការពារជាតិ អគ្គ-សេនាធិការ ក្រសួងមហាផ្ទៃ និងអគ្គនាយកនគរបាលជាតិ និងស្ថាប័នផ្សេងទៀត នៃរាជរដ្ឋាភិបាល អាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំរៀបចំបរិយាកាសនយោបាយ អព្យាក្រឹត និងសន្តិសុខ សំរាប់ការបោះឆ្នោត ។

I. បរិយាកាសនយោបាយអព្យាក្រឹត

ដែលហៅថា បរិយាកាសនយោបាយអព្យាក្រឹតឲ្យទៅបាន លុះត្រាតែគណបក្ស នយោបាយ ឥស្សរជននយោបាយមានសិទ្ធិ និង ឱកាសស្មើៗគ្នាក្នុងការចូលរួមជីវភាពនយោបាយ រាប់ទាំង យុទ្ធនាការបោះឆ្នោត ប្រជាជនមានសិទ្ធិបោះឆ្នោតជូនគណបក្សនយោបាយឬឥស្សរជន នយោបាយ ដែលខ្លួនពេញចិត្តដោយគ្មានការបង្ខិតបង្ខំ បំភិតបំភ័យ គំរាមកំហែង ។ ដើម្បីសំរេចបាននូវគោល ដៅនេះ ចាំបាច់ត្រូវចាត់វិធានការជាក់ស្តែងមួយចំនួន គឺ :

១-អព្យាក្រឹតភាពនយោបាយ ចំពោះកងកម្លាំងប្រដាប់អាវុធ និង រដ្ឋបាលស៊ីវិល

-កំលាំងប្រដាប់អាវុធ និង រដ្ឋបាលស៊ីវិលអព្យាក្រឹត្យ គឺជាយន្តការអចិន្ត្រៃយ៍ នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។ ដូចនេះ យន្តការនេះត្រូវស្ថិតនៅជាអព្យាក្រឹត និង ផ្តល់ការការពារចំពោះគ្រប់គណបក្សទាំងអស់ដែលរួមជីវភាពនយោបាយសង្គម និងយុទ្ធនាការបោះឆ្នោត ។ សេវាសាធារណៈត្រូវបានផ្តល់ជូនគ្រប់គណៈបក្សនយោបាយដោយគ្មានលំអៀង ដូចជាទីកន្លែងសំរាប់ប្រជុំ មិទិញ ការឃោសនាបោះឆ្នោត ការធ្វើដំណើរដោយគ្មានការហាមឃាត់ ការទទួលបាននូវការការពារសន្តិសុខ ពីកម្លាំងប្រដាប់អាវុធ ។ល ។

-ពាក្យអព្យាក្រឹតនៅទីនេះ គឺអព្យាក្រឹត្យមុខនាទី មិនមានន័យថា ដកសិទ្ធិបោះឆ្នោតចេញពីបុគ្គល នៅក្នុងកម្លាំងប្រដាប់អាវុធ ឬ រដ្ឋបាលស៊ីវិលឡើយ គេមានសិទ្ធិបោះឆ្នោតឱ្យគណបក្សនយោបាយ ឬតស្សរជននយោបាយដែលគេពេញចិត្ត ប៉ុន្តែគេមិនត្រូវប្រើប្រាស់មុខតំណែងក្នុងកម្លាំងប្រដាប់អាវុធ ឬ រដ្ឋបាលស៊ីវិល ធ្វើយុទ្ធនាការបោះឆ្នោត បំរើឱ្យគណបក្សនយោបាយណាមួយ ហើយប្រឆាំងជាមួយគណបក្សនយោបាយណាមួយឡើយ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ មាត្រាទី ៧៩ ជំពូកទី VII បានចែងពីវិសមភាពនៃសមាជិកសភា ជាមួយមុខងារសាធារណៈជាសកម្ម ដែល សំដៅសំខាន់ចំពោះកម្លាំងប្រដាប់អាវុធ និង រដ្ឋបាលស៊ីវិល ។ ដូចនេះ ទើបឆ្នាំ ១៩៩៣-១៩៩៤ មានការផ្លាស់ប្តូរសមាជិកសភាមួយចំនួន ដែលត្រូវចេញទៅបំពេញភារកិច្ចក្នុង កម្លាំងប្រដាប់អាវុធ និង រដ្ឋបាលដែនដី ខេត្ត- ក្រុង ។

២- សន្តិសុខសង្គម សណ្តាប់ធ្នាប់សាធារណៈ

- សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម មិនត្រឹមតែមានសារៈសំខាន់ចំពោះជីវភាពរស់នៅ ដ៏សុខសាន្តរបស់ប្រជាជន និង ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមប៉ុណ្ណោះទេ ប៉ុន្តែវាមានឥទ្ធិពលយ៉ាងសំខាន់ ទៅលើបរិយាកាសនៃការបោះឆ្នោត ដែលត្រូវប្រព្រឹត្តទៅដោយគ្មានហិង្សា គ្មាន ការបំភិតបំភ័យ ។

- ដើម្បីធានាឱ្យសន្តិសុខ សណ្តាប់ធ្នាប់សង្គមបានល្អ រួមចំណែកដល់ការបង្កើតបរិយាកាសនយោបាយអព្យាក្រឹតសំរាប់ការបោះឆ្នោត ចាំបាច់ត្រូវ :

ក- បន្តបង្ក្រាបចំពោះក្រុមប្លន់ប្រដាប់អាវុធ ការចាប់ជំរិតយកប្រាក់ បង្ក្រាបខ្សែបណ្តាញ និង កាត់ផ្តាច់ការរត់គ្រឿងញៀន ប្រាក់ក្លែងក្លាយ បំបិទចោលបនល្បែងខុសច្បាប់ ដែលជាប្រភពគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិសុខជាតិ ។

ខ- គ្រប់គ្រងឱ្យបានជាប់ និង ណែនទូវអាវុធជាតិផ្ទុះ ស្រាវជ្រាវ និង ដកហូតអាវុធជាតិផ្ទុះ ដែលប្រើប្រាស់ ឬ ដឹកជញ្ជូនដោយខុសច្បាប់ ។

- បំផ្លាញចោលនូវគ្រាប់មីន ដែលរឹបអូសបានកន្លងមក ។

- បំផ្លាញចោលអាវុធមួយចំនួន ដែលមិនចាំបាច់រក្សាទុកក្នុងវិស័យការពារជាតិ និង សន្តិសុខ(បង្ការកុំអោយអាវុធនេះចេញក្រៅឃ្លាំងចូលក្នុងដៃជនទុច្ចរិតបង្កវិនាសកម្មចំពោះ ប្រជា ជន និង សន្តិសុខជាតិ) ។

គ -បំបាត់ចោលប៉ុស្តិ៍ត្រួតពិនិត្យគ្មានច្បាប់ កាត់បន្ថយប៉ុស្តិ៍ត្រួតពិនិត្យដែលមានច្បាប់ ទាំងផ្លូវគោក ផ្លូវទឹក ផ្លូវដែក តែខ្វះប្រសិទ្ធភាព ហើយប្រព្រឹត្តអំពើអសកម្ម ។

ឃ - ប្រមូលអាវុធពីជីវពល ភូមិ - ឃុំ បញ្ចូលឃ្លាំង ឬ បំផ្លាញចោល ។ អាចរក្សាជីវពល តែក្នុងភូមិសាស្ត្រ ដែលខ្មែរក្រហមធ្វើសកម្មភាព តាមសំណើជាក់ស្តែងរបស់អគ្គសេនាធិការ ។

-ក្រសួងការពារជាតិ អគ្គសេនាធិការ ពិភាក្សាជាក់ស្តែងជាមួយក្រសួងមហាផ្ទៃ អគ្គនាយកនគរបាលជាតិ ដើម្បីកំណត់តំបន់ត្រូវប្រមូលអាវុធ ពីជីវពល តំបន់ត្រូវរក្សាទុក ចំនួនអាវុធ ប្រភេទអាវុធត្រូវរក្សាទុក និង ត្រូវបំផ្លាញចោល ។

ង- កំណត់ឡើងវិញនូវអ្នកដែលត្រូវប្រើប្រាស់អាវុធ បែបបទប្រើប្រាស់អាវុធ របៀបប្រើប្រាស់អាវុធ ។

ច - កំណត់អំពីរបបប្រើប្រាស់អង្គរក្ស អ្នកការពារ សំរាប់មន្ត្រីរាជការ កម្លាំងប្រដាប់អាវុធ មន្ត្រីនយោបាយ ទាំងវិនិយោគិន ពាណិជ្ជករ អាជីវករ ក្រុមហ៊ុន រោងចក្រ សហគ្រាស លំនៅដ្ឋាន ។ល ។

ឆ - ត្រួតពិនិត្យការផ្តល់ស្លាករថយន្តអោយស្របតាមតួនាទីសមត្ថកិច្ច ។ រថយន្តទាំងអស់ត្រូវបកបាំងខ្មៅដែលបិទលើកញ្ចក់ក្នុងរង្វង់ ០១ ខែ យ៉ាងយូរ (នេះជាផ្នែកមួយនៃឧក្រិដ្ឋកម្ម កន្លងមក) គឺត្រូវបកបាំងខ្មៅដែលបិទលើកញ្ចក់រថយន្តអោយអស់ជាស្ថាពរ ត្រឹមថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៧ ។

ជ-កំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ត្រូវអនុវត្តនូវបទបញ្ជារបស់ សហអគ្គ មេបញ្ជាការកង កំលាំងប្រដាប់អាវុធជាតិ នាយអគ្គសេនាធិការ នាយអគ្គនគរបាលជាតិ ទាំងទីតាំងឈរជើង ការចល័តកំលាំង ការធ្វើដំណើរ ការប្រើប្រាស់អាវុធ ការបំពេញបេសកកម្ម ការសប្បាយ កំសាន្ត ។ល។

- ធ្វើបាននូវកិច្ចការទាំង ០៨ ខាងលើនេះ នឹងរួមចំណែកច្រើន មិនគ្រាន់តែ សណ្តាប់ធ្នាប់ សង្គមសន្តិសុខជាតិប៉ុណ្ណោះទេតែនឹងបានពង្រឹងដល់ជំនឿទុកចិត្ត សំរាប់ការបោះឆ្នោតមួយ ដែលប្រព្រឹត្តទៅដោយសេរីត្រឹមត្រូវយុត្តិធម៌ បង្កើតបានជាបុព្វបទសំរាប់នីតិរដ្ឋ ប្រកបដោយ ប្រជាធិបតេយ្យពហុបក្សនាពេលអនាគត ។

II- ការកែទម្រង់ :

ការកែទម្រង់ គឺជាកិច្ចការដ៏ស្មុគស្មាញ ហើយត្រូវធ្វើយូរអង្វែង ។ ប៉ុន្តែកិច្ចការសំខាន់ ដែលត្រូវធ្វើនៅចំពោះមុខ ដែលអាចធ្វើទៅបាន គឺផ្តោតលើស្ថេរភាពនយោបាយ សន្តិសុខ សង្គម សណ្តាប់ធ្នាប់សាធារណៈ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយជោគជ័យ ជំរុញដល់ការរក្សា ស្ថេរភាពខាងម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា រក្សាល្បឿនកំណើន សេដ្ឋកិច្ច ។ ក្នុងនោះក្រៅ ពីកិច្ចការទាំង០៨ខាងលើ ក៏ត្រូវជំរុញការកែទម្រង់ខាងកងទ័ព ដោយបំបាត់ឱ្យអស់នូវ តួលេខចំនួនទ័ពខ្មោច (តួលេខបំប៉ោង) ដកចេញនូវយោធិនដែល មិនគ្រប់អាយុ ១៨ ឆ្នាំ ដោយឧបត្ថម្ភឱ្យគេបានទទួលការបណ្តុះបណ្តាលចំណេះទូទៅ ឬ វិជ្ជាជីវៈ ជួយផ្តល់ទុនឱ្យគេបានប្រកបមុខរបរជាជនស៊ីវិល ។

ទទួលបានសារាចរនេះ រាជរដ្ឋាភិបាល សូមស្នើគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរ ដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវខិតខំផ្សព្វផ្សាយ និងរៀបចំបទដ្ឋានគតិយុត្ត ដើម្បីអនុវត្តដោយ ស្មារតីទទួលខុសត្រូវខ្ពស់នូវភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាព រួចរាយការណ៍អំពីលទ្ធផល ជូន មកទីស្តីការ គណៈរដ្ឋមន្ត្រី តាមករណីជាក់ស្តែងនីមួយៗ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត **ហ៊ុន សែន**

***

III- សេចក្តីសម្រេចក្រសួង

១ នីតិវិធីរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ប្រកាស

ប្រកាសលេខ ៧៧៨ ឧប ក ផក ចុះថ្ងៃទី២៥ ខែ សីហា ឆ្នាំ ១៩៩៧

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ហ្គោលដិតិក (ខេមបូឌា) ហ្គាម៉ិនធី មែនញូហ្វាក់ធីរីង អិលធីឌី (GOLDTEX (Cambodia) GARMENT MANUFACTURING LTD) តំណាងដោយលោក LEE YUET KAU សញ្ជាតិអង់គ្លេស ភេទប្រុស អាយុ ៣៦ ឆ្នាំ អាសយដ្ឋាន 4\F, WING MING IND CENTRE , 15 CHEUNG YUE , ST CHEUNG SHA WAN KOWLOON, HONG KONG កាន់លិខិតឆ្លងដែន លេខ 610107144 ចុះថ្ងៃទី 15. 8 91 បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា "ហ្គោលដិតិក(ខេមបូឌា) ហ្គាម៉ិនធី មែនញូហ្វាក់ធីរីង អិលធីឌី" មានទីតាំងស្ថិតនៅ អតីតរោងចក្រអារឈើចាក់អង្រែ ដីឡូត៍លេខ ៥២២ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និង គំរោងសិក្សាបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិដ្ឋាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យផលិតនូវ " សំលៀកបំពាក់ " ទៅតាមគំរូដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ឬល្មើសធូន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

***

២. រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ សីហា ឆ្នាំ ១៩៩៥

សេចក្តីសំរេច លេខ២៤៨៦ សសរ មខ ប្រខ

ស្តីពី ការបែងចែកសិស្ស និស្សិតចំនួន១៤នាក់

ដែលទើបបញ្ចប់ការសិក្សាពីបរទេស

***

រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ន.ស/៩៤ ចុះថ្ងៃទី២០កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- យោងលិខិតលេខ៣១៩ សជណ/ផក ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សំរេច

ប្រការ ១ : អ្នកបច្ចេកទេសថ្នាក់ឧត្តមចំនួន ១៤នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស ត្រូវបានបែងចែកឱ្យ ទៅបំរើការងារនៅតាមក្រសួង ស្ថាប័នមួយចំនួន ដូចមានក្នុងតារាងឧបសម្ព័ន្ធនៃសេចក្តី សំរេចនេះ ។

ប្រការ ២ : ក្រសួងស្ថាប័នដែលពាក់ព័ន្ធមានភារកិច្ចទទួលយកអ្នកបច្ចេកទេសទាំងនេះ ដើម្បីរៀបចំការងារឱ្យត្រូវតាមមុខជំនាញនិងផ្តល់បៀវត្សជូនសាមីខ្លួន ចាប់ពីថ្ងៃដែល បានចូលបំរើការងារជាផ្លូវការ ។

ប្រការ ៣ : សេចក្តីសំរេចនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឈ្នាក់ សុខ

***

ព្រះរាជាណាចក្រកម្ពុជា

គណៈរដ្ឋមន្ត្រី

ជាតិ សាសនា ព្រះមហាក្សត្រ

លេខាធិការដ្ឋានមុខងារសាធារណៈ

តារាងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ៤៨៦ សសរ/មស/ក្រខ ចុះថ្ងៃទី២៩ ខែ៨ ឆ្នាំ១៩៩៧

ស្តីពីការបែងចែកនិស្សិតចំនួន ១៤នាក់ ដែលបានបញ្ចប់ការសិក្សាពីបរទេស

ល.រ	នាមត្រកូល និងនាមខ្លួន	ភេទ	ថ្ងៃ ខែ ឆ្នាំ កំណើត	អង្គភាព ដើម	មុខជំនាញ បច្ចេកទេស	កំរិតបណ្តុះ បណ្តាល	បៀវត្ស	ប្រភពបណ្តុះ បណ្តាល
១.ក្រសួងសាធារណការនិងដឹកជញ្ជូន ចំនួន ៤ នាក់								
១	ឡេង ឆេង	ប្រុស	០១-៣-៧៣	សិស្ស	សំ/ស្ពានថ្នល់	ឧត្តម	៩០% ឧ១	វៀតណាម
២	ខាន់ រ៉ា	ប្រុស	២៩-១២-៧៣	សិស្ស	សំ/ស្ពានថ្នល់	ឧត្តម	៩០% ឧ១	វៀតណាម
៣	ឃួន សេរីរុធ	ប្រុស	០៧-៤-៧០	សិស្ស	សំ/[illegible]ស្ពានថ្នល់	ឧត្តម	៩០% ឧ១	វៀតណាម
៤	ឡៃ ធី	ប្រុស	២៧-៩-៦៩	សិស្ស	សំ/ស្ពានថ្នល់	ឧត្តម	៩០% ឧ១	វៀតណាម
២.ក្រសួងសុខាភិបាល ចំនួន ៤នាក់								
៥	ម៉េង ហួត	ប្រុស	១៤-៤-៦៩	សិស្ស	វេជ្ជសាស្ត្រ	ឧត្តម	៩០% ឧ១	វៀតណាម
៦	ប្លង់ ធំ	ប្រុស	១២-៩-៦៩	សិស្ស	វេជ្ជសាស្ត្រ	ឧត្តម	៩០% ឧ១	វៀតណាម
៧	យឹម ផុង	ប្រុស	០១-០១-៧៣	សិស្ស	វេជ្ជសាស្ត្រ	ឧត្តម	៩០% ឧ១	វៀតណាម
៨	សុត សឿង	ប្រុស	៧-៤-៧៤	សិស្ស	វេជ្ជសាស្ត្រ	ឧត្តម	៩០% ឧ១	វៀតណាម
៣. ក្រសួងផែនការ ចំនួន ៣នាក់								
៩	ឡាយ ជ្រាវ	ប្រុស	០១-១០-៧២	សិស្ស	សេ.ព.ក្រប្រ	ឧត្តម	៩០% ឧ១	វៀតណាម

១០	ចាន់ សារ៉ាវុធ	ប្រុស	១០-៣-៧២	សិស្ស	សេ.ព.ក្រប្រ	ឧត្តម	៩០% ឆ១	វៀតណាម
១១	ឃី ភិរម្យ	ប្រុស	២២-៨-៧១	សិស្ស	សេ.ព.ក្រប្រ	ឧត្តម	៩០% ឆ១	វៀតណាម
៤. ក្រសួង ពាណិជ្ជកម្ម ចំនួន ២នាក់								
១២	ផេង ដារុំធ	ប្រុស	០២-០២-៧៤	សិស្ស	សេ.ព.ក្រប្រ	ឧត្តម	៩០% ឆ១	វៀតណាម
១៣	យួន វីរៈ	ប្រុស	១២-១១-៧៣	សិស្ស	សេ.ព.ក្រប្រ	ឧត្តម	៩០% ឆ១	វៀតណាម
៥. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ១នាក់								
១៤	ហាស់ សំបូរ	ប្រុស	៥-១០-៧២	សិស្ស	កុំព្យូទ័រ	ឧត្តម	៩០% ឆ១	វៀតណាម

បានបញ្ឈប់បញ្ជីនេះត្រឹមចំនួន ១៤ (ដប់បួន) នាក់ប៉ុណ្ណោះ

ភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៩៧

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ទ្រាក់ សុខ

***

បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៧៥០ រៀល